ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ញត្តិករទូរគមនាគមន៍កម្ពុជា

លេខ :...១១៩៧.....ប.ក.ទ.ក.

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី**

**ប្រធានក្រុមហ៊ុនទូរគមនាគមន៍ទាំងអស់**

**កម្មវត្ថុ** ៖ សុំលុបចោលស៊ីមកាតទូរស័ព្ទដែលដំណើរការ មិនមានអត្តសញ្ញាណបណ្ណ ឬ លិខិតបញ្ជាក់អត្តសញ្ញាណ ។

**យោង** ៖ - ចំណារដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ លើលិខិតលេខ១០៥១ ប.ក.ទ.ក. ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ របស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ។

- សារាចរលេខ ០០១ ស.រ មផ-បទ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា សូមជម្រាបជូនឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីប្រធានក្រុមហ៊ុនទូរគមនាគមន៍ទាំងអស់ ជ្រាបថា៖ ពួកឧក្រិដ្ឋជន និងជនទុច្ចរិតបានប្រើប្រាស់មធ្យោបាយតាមបច្ចេកវិទ្យាទូរគមនាគមន៍ ដើម្បីធ្វើសកម្មភាពភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន អំពើឆក់ប្លន់ ចាប់មនុស្សជំរិតទារប្រាក់ អំពើឃាតកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស បទល្មើសសេដ្ឋកិច្ច លួចដំឡើង និងធ្វើអាជីវកម្មលើប្រព័ន្ធទូរគមនាគមន៍ខុសច្បាប់គ្រប់រូបភាព ការបញ្ជូនផ្សព្វផ្សាយរូបភាពអាសអាភាស និងអំពើអនាចារផ្សេងៗទៀត ដែលធ្វើឱ្យប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណីដ៏ល្អ និងសីលធម៌សង្គម ។

ហេតុដូចនេះដើម្បីរួមចំណែក ការពារសុវត្ថិភាព និងគោរពឱ្យបានតាមសារាចរអន្តរក្រសួងលេខ០០១ ស.រ មផ-បទ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា សូមឱ្យប្រតិបត្តិករផ្តល់សេវាទូរស័ព្ទចល័តទាំងអស់ លុបចោលជាបន្ទាន់នូវរាល់ស៊ីមកាតទូរស័ព្ទទាំងឡាយណាដែលមិនមានអត្តសញ្ញាណបណ្ណ ឬ លិខិតបញ្ជាក់អត្តសញ្ញាណចាប់ពី ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ នេះតទៅជាកំហិត។ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា នឹងសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីធ្វើការត្រួតពិនិត្យ និងអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីប្រធានក្រុមហ៊ុនទូរគមនាគមន៍ទាំងអស់មេត្តាជ្រាប និងអនុវត្តតាមខ្លឹមសារនៃលិខិតនេះដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។

សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីប្រធានក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ទាំងអស់ទទួលនូវការរាប់អានអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០១៥

**ប្រធាន**

ម៉ៅ ចរិយា

**ចម្លងជូន៖**

- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងមហាផ្ទៃ

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ